#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia
+855 (0)77 374 110
www.sasabassac.com

# សេចក្តីប្រកាសព័ត៌មាន

សំរាប់ការផ្សាយបន្ទាន់

ថ្ងៃសុក្រ ទី ១៣ ខែឧសភា ឆ្នាំ ២០១១

## ស-សបាសាក់ សូមបង្ហាញជូននូវពិព័រណ៍សិល្បៈក្រោមចំណងជើងថា *ធម្មតា* ដោយ វុធ លីណូ



Vuth Lyno, *Lion*, 2011, Digital C-Print, 60x90cm

**ភ្នំពេញ** - ស-សបាសាក់ សូមជម្រាបជូនដំណឹងស្តីអំពីពិព័រណ៍សិល្បៈរបស់ វុធ លីណូ ក្រោមចំណងជើងថា «*ធម្មតា*»។

*ធម្មតា* រួមមានរូបថតពណ៌ធម្មជាតិខ្នាតធំចំនួន ៩ ផ្ទាំងព្យួរពីពិតានជារាងរង្វង់ ហើយភ្ជាប់ជាមួយនូវសំលេង។ ពិព័រណ៍នេះ ចោទសួរអំពីព្រំដែនរវាង ភាពជាឯកជននិងសារធារណៈ ភាពក្នុងនិងក្រៅ ពីព្រោះរូបដូចគ្នាបង្ហាញនៅខាងក្នុងរង្វង់ផងនិងខាងក្រៅរង្វង់ផង ប៉ុន្តែទំនាក់ទំនងរវាងអ្នកនិងរូបថតទាំងនេះខុសគ្នា។ នៅខាងក្រៅរង្វង់ អ្នកអាចស្វែងយល់អំពីរូបថតទាំងនេះម្តងមួយៗ។ ពេលនៅក្នុងរង្វង់ រូបថតទាំងអស់សំលឹងមើលមកអ្នកព្រមពេលជាមួយគ្នា។ រូបថតនីមួយៗ មានឧបករណ៍សម្រាប់ស្តាប់សំលេង ដែលក្នុងនោះបុគ្គលនៅក្នុងរូបថតនិយាយដោយស្មោះត្រង់អំពីជីវិតរបស់គេ។ អ្នកអាចស្តាប់រឿងទាំងនេះម្តងមួយៗ។ ទំនាក់ទំនងរវាងអ្នកនិងបុគ្គលនៅក្នុងរូបថត គឺកើតឡើងមួយម្តងក្នុងពេលតែមួយ។

រូបថត និងសាច់រឿងនៅក្នុងពិព័រណ៍ *ធម្មតា* គឺជាលទ្ធផលនៃសិក្ខាសាលាមួយដែលលីណូរៀបចំឡើងជាមួយនិងអ្នកសំរបសំរួលជំនាញម្នាក់ និងបុរសស្រលាញ់បុរស (MSM) ខ្មែរចំនួន ៩ នាក់។ ពួកគេបានចែករំលែក

រឿងរ៉ាវជីវិតផ្ទាល់ខ្លួនរបស់ពួកគេក្នុងរយៈពេល ២ ថ្ងៃ ក្នុងគោលបំណងបង្កើតកិច្ចសន្ទនាដ៏ស្និទ្ធស្នាលមួយជាមួយនិងសាធារណជន ស្តីអំពីក្រុមអ្នកស្រលាញ់ភេទដូចគ្នា និងអ្នកស្រលាញ់ទាំងពីរភេទ (LGBT)។

នៅចុងបញ្ចប់នៃសិក្ខាសាលា អ្នកចូលរួមទាំង ៩ នាក់ ត្រូវបានស្នើអោយគូរមុខរបស់គេដោយខ្លួនគេផ្ទាល់ ដើម្បីបញ្ជាក់អំពីអត្តសញ្ញាណរបស់គេរៀងៗខ្លួន។ លទ្ធផលទទួលបានគឺ ម៉ាស់ដែលមាននិមិត្តសញ្ញាប្រកបដោយអត្ថន័យ និងមានលក្ខណៈផ្ទាល់ខ្លួនផ្សេងៗដូចជា រូបសត្វ ទេសភាព និងទង់ជាតិប្រទេសកម្ពុជាជាដើម។ មុខមួយ មានរូបបែបអរូបីនិងរង្វង់ជាច្រើន ដែលសំដៅលើវដ្តនៃជីវិត។ មុខមួយមានរូបឆ្មា តំណាងអោយការស្រលាញ់របស់គាត់ចំពោះសត្វនេះ និងបុគ្គលិកលក្ខណៈរបស់គាត់ដែលស្រដៀងគ្នានឹងសត្វឆ្មា។ បុរសនៅពីក្រោយម៉ាស់រូបគោ យល់ថាគាត់ខុសពីគោត្រង់ថាគាត់មិនរករឿងអ្នកណាមុនឡើយ បើគេមិនរករឿងគាត់មុនទេនោះ។ រូបមេអំបៅ មួយចំហៀងមានពណ៌មួយចំហៀងសខ្មៅ បញ្ជាក់ពីសេចក្តីរីករាយនិងទុក្ខសោកដែលយើងទាំងអស់គ្នាឆ្លងកាត់។ រូបយក្ស ដែលជាតួអង្គកាចសាហាវនៅក្នុងរឿងព្រេង គឺតំណាងអោយភាពខ្លាចរអារបស់សាធារណជនចំពោះក្រុម LGBT។ រូបភ្នំនិងផ្កា គឺជានិមិត្តសញ្ញានៃផ្ទះនិងក្រុមគ្រួសារ ដែលម្ចាស់រូបតំណាងដោយស្លឹកឈើ ហើយនឹងក្លាយទៅជាផ្កានៅថ្ងៃណាមួយ។ រូបទង់ជាតិ រំលឹកដល់មោទនភាពជាតិ និងចិត្តសប្បុរសរបស់ខ្មែរ។ និមិត្តសញ្ញាទាំងនេះ បង្ហាញពីទំរង់ដ៏សម្បូរបែបនៃអត្តសញ្ញាណរបស់ MSM ខ្មែរ។

សំរាប់សិល្បករ ការរៀបចំរូបថតជារាងរង្វង់បែបនេះ «តំណាងអោយស្មារតីសហគមន៍ និងដំណើរការនៃសិក្ខាសាលា ដែលអ្នកចូលរួមទាំងអស់បានមកចែករំលែក និងរៀនសូត្រពីគ្នាទៅវិញទៅមក»។ រង្វង់នៅខាងក្នុងតំណាងអោយភាពឯកជនផ្ទាល់ខ្លួន ដែលពួកគេចង់ចែករំលែកដល់ពិភពខាងក្រៅ។ លីណូ បញ្ជាក់ថាសហគមន៍នេះ «នៅមិនទាន់ពេលលេញនៅឡើយទេ»។ មានចន្លោះមួយនៅក្នុងរង្វង់ សម្រាប់អ្នកទស្សនាអាចដើរចូលបាន ហើយ «ចន្លោះនេះគឺសម្រាប់អ្នកដែលចង់ចូលរួមចំនែកគាំទ្រនៅក្នុងសហគមន៍នេះ»។ ពិព័រណ៍នេះ បំផុសអោយយើងរិះគិតឡើងវិញនូវទស្សនៈមិនសមហេតុផលដែលមានទៅលើក្រុម MSM ហើយផ្តល់អំណាចដល់ពួកគេតាមរយៈការឆ្លុះបញ្ចាំងអំពីអត្តសញ្ញាណរបស់ខ្លួន។

ចំណងជើងរបស់ពិព័រណ៍នេះ គឺជាពាក្យដែលតែងតែត្រូវបានប្រើប្រាស់ជាទូទៅ «*ធម្មតា*»។ តួអង្គនៅក្នុងរូបថតប្រាប់យើងអំពីជីវិតធម្មតាប្រចាំថ្ងៃរបស់ពួកគេ។ នៅពេលដែលរៀបរាប់អំពីដំណើរការថតរូបអោយអ្នកចូលរួមម្នាក់ៗ លីណូរំលឹកថា «ខ្ញុំបានប្រាប់គាត់ថា គាត់គ្រាន់តែធ្វើអារម្មណ៍ធម្មតា ហាក់ដូចជាមាននរណាម្នាក់កំពុងនិយាយជាមួយគាត់អញ្ចឹង ដែលនេះជាអារម្មណ៍ដែលខ្ញុំចង់បង្កើតឡើងនៅក្នុងការរៀបចំដំឡើងពិព័រណ៍ចុងក្រោយ គឺពួកគាត់និយាយជាមួយនិងអ្នកទស្សនា»។

គម្រោងរបស់លីណូ មានលក្ខណៈសហការគ្នា។ កត្តាចម្បងនៅពេលថតរូបទាំងនេះគឺ «ដើម្បីអោយអ្នកចូលរួមទាំងនេះក្លាយជាអ្នកបង្កើតរឿងរ៉ាវរបស់គេដោយខ្លួនគេផ្ទាល់ គឺពួកគេគឺជាសិល្បករ»។ លីណូ មានបំណងឆ្លុះបង្ហាញពីបុគ្គលភាពរបស់តួអង្គម្នាក់ៗ ដែលជាផ្នែកមួយនៃ «សហគមន៍ដូចគ្នាតែមួយ ប៉ុន្តែនៅក្នុងនោះមានភាពសំបូរបែប»។ លីណូ បន្ថែមថា «ខ្ញុំចង់អោយរូបថតទាំងនេះមានលក្ខណៈសាមញ្ញ ដូចជារូបថតនៅក្នុងលិខិតឆ្លងដែនអញ្ចឹង»។ ការងារសិល្បៈដំឡើង (Installation) របស់លីណូ គឺជាលិខិតឆ្លងដែនសំរាប់ចូលទៅកាន់រឿងរ៉ាវ និងជីវិតដ៏ស្មុគស្មាញមួយចំនួន។ អ្នកទស្សនា សិល្បករ និងតួអង្គនៅក្នុងរូបថត ទាំងអស់គ្នាធ្វើអោយដំណើរការនៃការសហការនេះពេញលេញ។

-- អត្ថបទដោយ វៀត លេ អ្នករៀបចំពិព័រណ៍សិល្បៈឯករាជ្យ អ្នកនិពន្ធ និងសិល្បករ។

**អំពីសិល្បករ៖**

វ៉ុធ លីណូ (កើតនៅឆ្នាំ ១៩៨២ នៅភ្នំពេញ) ប្រើប្រាស់រូបថតដើម្បីចោទសួរ និងសិក្សាស្វែងយល់អំពីគំនិតនៃការផ្លាស់ប្រែ និងការវិវត្តន៍របស់សង្គម។ ពិព័រណ៍របស់គាត់កន្លងមករួមមាន *កម្លាំងឆក់ស្រូបៈ គម្រោងសិល្បៈផ្សព្វផ្សាយនិងរូបថតសហសម័យ អាស៊ាន-កម្ពុជា* (២០០៩, វិចិត្រសាលដូល, ទីក្រុងសេអ៊ូល), *ពិព័រណ៍រូបថតភ្នំពេញ* (២០០៨, មជ្ឈមណ្ឌលវប្បធម៌បារាំង, ទីក្រុងភ្នំពេញ), *១៤+១* (២០០៧, មជ្ឈមណ្ឌលវប្បធម៌បារាំង,ទីក្រុងភ្នំពេញ)។ លីណូ ទទួលបានបរិញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រសង្គម (សាកលវិទ្យាល័យ RMIT ទីក្រុងមែលប៊ន ឆ្នាំ២០០៩)។ លីណូ ជាអ្នកធ្វើការផ្នែកអភិវឌ្ឍន៍ ជានាយកនៃគម្រោងសិល្បៈស-ស ហើយគាត់បានសហការរៀបចំពិព័រណ៍សិល្បៈ និងពិធីផ្សេងៗជាច្រើននៅក្នុងប្រទេសកម្ពុជា។

**អំពីស-សបាសាក់៖**

ស-សបាសាក់ គឺជាវិចិត្រសាល និងមណ្ឌលធនធានមួយ ដែលប្តេជ្ញាក្នុងការបង្កើត សម្របសម្រួល និងចែករំលែកវប្បធម៌ទស្សសិល្បៈសហសម័យនៅក្នុងនិងចេញពីប្រទេសកម្ពុជា។

*ធម្មតា* គឺជាផ្នែកមួយនៃកម្មវិធីមោទនភាពក្រុមអ្នកស្រលាញ់ភេទដូចគ្នា និងអ្នកស្រលាញ់ទាំងពីរភេទ (LGBT) នៅកម្ពុជា ឆ្នាំ ២០១១។ កម្មវិធីនេះ មានគោលបំណងផ្តល់ឪកាសដល់ក្រុម LGBT ខ្មែរ អោយជួបជុំគ្នា ប្រារព្ធ និងមានមោទនភាពចំពោះអត្តសញ្ញាណរបស់ពួកគេ។ វាក៏ជាឪកាសសំរាប់អ្នកដទៃទៀតដើម្បីស្វែងយល់អំពីបញ្ហារបស់ក្រុម LGBT ខ្មែរ និងលើកកម្ពស់ការយល់ដឹងនិងការគោរព។

**ព័ត៌មានលំអិត៖**

| | |
|---|---|
| ពិព័រណ៍៖ | *ធម្មតា* ដោយ វ៉ុធ លីណូ |
| បើកសម្ពោធ៖ | ថ្ងៃទី ១៧ ខែឧសភា វេលាម៉ោង ៦ ដល់ ៨ យប់ |
| ពិព័រណ៍បើក៖ | ពីថ្ងៃទី ១៧ ខែឧសភា ដល់ ថ្ងៃទី ១២ ខែមិថុនា |
| ម៉ោងទស្សនា៖ | ថ្ងៃព្រហស្បត៏ និងសុក្រ ម៉ោង ២-៦ ល្ងាច ថ្ងៃសៅរ៍ និងអាទិត្យ ម៉ោង ១០ ព្រឹក - ៦ ល្ងាច |
| ទីតាំង៖ | ស-សបាសាក់ នៅផ្ទះលេខ ១៨ ជាន់ទី២ មហាវិថីសុធារស ភ្នំពេញ |
| គេហទំព័រ៖ | www.sasabassac.com |

**ទំនាក់ទំនង៖**

អេរីន ឃ្លីសុន
នាយកផ្នែកសិល្បៈនៃស-សបាសាក់
ទូរសព្ទ័ +៨៥៥ (០)១២ ៥០៧ ៩១៧
អ៊ីមែល erin@sasabassac.com